# តើអេសាយគឺជានរណា ?

នៅក្នុងព្រះគម្ពីរមរមន យើងបានអានពាក្យសម្ដីរបស់បុរសម្នាក់ឈ្មោះ អេសាយ ។ អេសាយ គឺជាព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ លោកបានរស់នៅពីមុនព្រះយេស៊ូវគ្រីស្ទបានប្រសូតមក ។



អេសាយបានបង្រៀនអំពីព្រះជន្មរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកបានមានប្រសាសន៍ថាព្រះយេស៊ូវនឹងនាំមកនូវសេចក្ដីសុខសាន្តដល់ពិភពលោកនេះ ។ លោកបានបង្រៀនថាព្រះយេស៊ូវនឹងសុគត មានព្រះជន្មរស់ឡើងវិញ ហើយយាងមកផែនដីវិញនៅថ្ងៃណាមួយ ។



រាប់រយឆ្នាំក្រោយមក នីហ្វៃបានសរសេរពាក្យរបស់អេសាយនៅក្នុងព្រះគម្ពីរមរមនដើម្បីបង្រៀនយើងអំពីព្រះយេស៊ូវគ្រីស្ទ ។ នៅពេលព្រះយេស៊ូវបានយាងទៅជួបពួកសាសន៍នីហ្វៃ ទ្រង់បានចែកចាយពាក្យសម្ដីរបស់អេសាយ ។ ទ្រង់បានសុំឲ្យយើងសិក្សាអំពីពាក្យទាំងនោះ ។ នៅពេលយើងសិក្សាពាក្យរបស់អេសាយ យើងអាចមានអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ហើយខិតកាន់តែជិតទ្រង់ ។



## ការសាកល្បងព្រះគម្ពីរ

សូមអាន នីហ្វៃទី ២ ១៩:៦ ។ តើមានឈ្មោះប៉ុន្មានសម្រាប់ព្រះយេស៊ូវនៅក្នុងខគម្ពីរនេះ ?

តើសត្វអ្វីដែលបង្ហាញថាព្រះវិញ្ញាណបរិសុទ្ធគង់នៅឯពិធីបុណ្យជ្រមុជទឹករបស់ព្រះអង្គសង្គ្រោះ ?
គន្លឹះ៖ នីហ្វៃទី ២៣១:៨

តើនរណាខ្លះនឹងត្រូវបានរស់ឡើងវិញ ?
គន្លឹះ៖ អាល់ម៉ា ១១:៤៤

### ខ្ញុំចេះអានព្រះគម្ពីរមរមន !

បន្ទាប់ពីប្អូនអាន សូមផាត់ពណ៌រូបភាពនេះ ។ ប្អូនអាចអានខគម្ពីរទាំងនេះដែលត្រូវទៅនឹងអំណានប្រចាំសប្ដាហ៍នីមួយៗ មកពីសៀវភៅ*ចូរមកតាមខ្ញុំ* ៖

សប្ដាហ៍ទី ១ ៖ នីហ្វៃទី ២ ១១:២

សប្ដាហ៍ទី ២ ៖ នីហ្វៃទី ២ ២៤:៣

សប្ដាហ៍ទី ៣ ៖ នីហ្វៃទី ២ ២៦:២៣-២៤

សប្ដាហ៍ទី ៤ ៖ នីហ្វៃទី ២ ៣២:៥

សប្ដាហ៍ទី ៥ ៖ នីហ្វៃទី ២ ៩:១៣



អេសាយបានបង្រៀនថា ព្រះយេស៊ូវគឺជា « ម្ចាស់នៃមេត្រីភាព »( នីហ្វៃទី ២ ១៩:៦ ) ។ គូរ ឬថតរូបអ្វីដែលជួយប្អូនឲ្យមានអារម្មណ៍សុខសាន្ត ។
ផ្ញើរូបថតរបស់ប្អូនទៅកាន់ទស្សនាវដ្ដី *ព្រើយមិត្ត* !
សូមមើលក្របខាងក្រោយដើម្បីដឹងអំពីរបៀបធ្វើ ។